# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា

~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៣០អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី១នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញបន្ថែមក្នុងរចនាសម្ព័ន្ធនៃអនុក្រឹត្យលេខ៣០អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា ២.-**

នៅតាមឃុំ សង្កាត់នីមួយៗ មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ដែលមានសមាសភាព ៖

| | |
|---|---|
| ១-មេឃុំ ឬចៅសង្កាត់ | ប្រធាន |
| ២-ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ | អនុប្រធាន |
~~~~~~~

| | |
|---|---|
| ៣-ប្រធានប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ សង្កាត់ | សមាជិក |
| ៤-ប្រធានកម្រងសាលាបឋមសិក្សា | សមាជិក |
| ៥-ប្រធានមណ្ឌលសុខភាព ឃុំ សង្កាត់ | សមាជិក |
| ៦-ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ | សមាជិក |
| ៧-អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា | សមាជិក |
| ៨-ភ្នាក់ងារសុខភាពសត្វ | សមាជិក |
| ៩-គ្រូវិទ្យាចារ្យក្នុងឃុំ សង្កាត់ | សមាជិក |
| ១០-ប្រធានភូមិ គ្រប់ភូមិ | សមាជិក |
| ១១-ស្មៀនឃុំ សង្កាត់ | សមាជិក និងជាលេខាធិការ ។ |

**មាត្រា ៣.-**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ មានតួនាទី និងភារកិច្ច :

-អនុវត្តគោលនយោបាយជាតិដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ

-ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ អំពីគ្រោះមហន្តរាយជាយថាហេតុ

-ធ្វើរបាយការណ៍ជាបន្ទាន់អំពីស្ថានភាពគ្រោះមហន្តរាយជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង អំពីទំហំនៃការខូចខាត និងតម្រូវការជាក់ស្តែងផ្សេងៗតាមករណីនីមួយៗ

-ធ្វើប្រតិបត្តិការជួយសង្គ្រោះប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ពេលមានគ្រោះមហន្តរាយកើតឡើង

-ជាសេនាធិការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ ក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នអង្គភាពពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនៅមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន

-រៀបចំចងក្រងក្រុមប្រតិបត្តិការសម្រាប់ធ្វើសកម្មភាពរួមមាន : ១-ក្រុមសន្តិសុខ រុករក និងសង្គ្រោះ ២-ក្រុមសុខភាព និងអនាម័យ ៣-ក្រុមឆ្លើយតប និងព័ត៌មាន

-ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារក្នុងក្រុមប្រតិបត្តិការទាំងបីខាងលើ

-រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំងបីលើជំនាញទទួលខុសត្រូវ ព្រមទាំងអប់រំ ផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ពីគ្រោះភ័យនៃគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ វិធានការគ្រប់គ្រងគ្រោះភ័យ

-ផ្តល់ព័ត៌មានដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខណ្ឌ និងខេត្ត ក្រុង អំពីការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ជាបន្ទាន់

-លើកគម្រោងប្រើប្រាស់ថវិកា សម្ភារៈ បរិក្ខារ មធ្យោបាយប្រើប្រាស់ និងកម្លាំងសម្រាប់ធ្វើសកម្មភាពតាមដំណាក់កាលនីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដាក់ស្នើទៅថ្នាក់លើ និងទៅអង្គការនានា

-ធ្វើការប្រជុំមួយខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាព និងដោះស្រាយបញ្ហាដែលកើតមានរបស់ក្រុមប្រតិបត្តិការទាំងបី និងធ្វើការប្រជុំបន្ទាន់ក្នុងលក្ខណៈមានគ្រោះអាសន្ន។ ការប្រជុំនេះត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់អភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
អនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**ញឹម វណ្ណដា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ